Son Chhay requests visitation with Tim Sakhorn in the Vietnamese prison.
Thach Setha: VN ambassador to Cambodia misleads the truth.
Sralanh Khmers 08/28/07

សារព័ត៌មាន ស្រឡាញ់ខ្មែរ
Srâlanh Khmer
ថ្ងៃអង្គារ ទី២៨ ខែសីហា ឆ្នាំ២០០៧

# សុន ឆ័យស្នើជួបទឹម សាខននៅគុកយួន ថាច់ សេដ្ឋាថាៈ អគ្គរដ្ឋទូតយួននៅកម្ពុជាបំភ្លៃការពិត

**ដោយៈ ក.និមល**

នៅថ្ងៃទី២៧ សីហា ២០០៧ លោកសុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាប្រធានគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាបានផ្ញើសំណើទៅលោកង្វៀន ចៀនថាំង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជាដើម្បីពិភាក្សាការងារមួយចំនួននិងសុំការអនុញ្ញាតឱ្យរូបលោក និងសហការីបានចុះទៅជួបដោយផ្ទាល់ជាមួយលោកទឹម សាខន(អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង ស្រុកគីរីវង់ ខេត្តតាកែវ)ដែលឥឡូវកំពុងជាប់ពន្ធនាគារនៅក្នុងប្រទេសវៀតណាម។ ជាមួយគ្នានេះ លោកថាច់ សេដ្ឋា នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោមក៏បានចេញសេចក្តីថ្លែងការណ៍ដោយសំដែងសេចក្តីសោកស្តាយចំពោះប្រសាសន៍របស់លោកង្វៀន ចៀនថាំងដែលបានបំភ្លៃការពិត បំភ័ន្តសាធារណមតិអំពីការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសវៀតណាមដែរ។

លោកសុន ឆ័យបានសរសេរជូនលោកង្វៀន ចៀនថាំងថា ដូចមន្ត្រីជំនួយការគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាបានទាក់ទងទៅស្ថានទូតឯកឧត្តមនាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧នេះស្រាប់ ស្នើសុំពេលវេលាដើម្បីជួបពិភាក្សាការងារផ្ទាល់ជាមួយឯកឧត្តមលើកិច្ចការមួយចំនួនក្នុងនោះមានករណីពាក់ព័ន្ធនឹងសំណើទស្សនកិច្ចនៃគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាវៀតណាមមកកម្ពុជាដែលបានស្នើឡើងដោយអនុប្រធានគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភាវៀតណាម ក្នុងឱកាសនៃកិច្ចប្រជុំAIPAនៅប្រទេសម៉ាឡេស៊ីពីថ្ងៃទី១៨ដល់២៣ ខែសីហា ឆ្នាំ២០០៧កន្លងទៅ និងបញ្ហា សំខាន់មួយចំនួនពាក់ព័ន្ធនឹងពលរដ្ឋនិងព្រះសង្ឃខ្មែរកម្ពុជាក្រោម។

លិខិតបន្តថា"ដោយបានទទួលពតិមានថា ឯកឧត្តមមិនអាចជួបខ្ញុំនិងសហការីក្នុងគណៈកម្មការបរទេសនៃរដ្ឋសភាបានក្នុងសប្តាហ៍នេះ ដោយហេតុថា ឯកឧត្តមជាប់រវល់រៀបចំពិធីបុណ្យឯករាជ្យជាតិរបស់វៀតណាមនោះខ្ញុំសង្ឃឹមថា ឯកឧត្តមនឹងព្រមព្រៀងឱ្យមានការជួបពិភាក្សាការងារនៅថ្ងៃខាងមុខឱ្យបានឆាប់តាមដែលអាចធ្វើបាន ព្រោះមានសារៈសំខាន់សំរាប់កិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋាភិបាល និងសភានៃប្រទេសទាំងពីរ។"

ជាមួយគ្នានេះ. លិខិតសរសេរថាដោយមានការស្នើសុំពីសំណាក់ប្រជាពលរដ្ឋខ្មែរជាច្រើនរូបសុំឱ្យខ្ញុំចុះទៅជួបដោយផ្ទាល់ជាមួយលោកទឹម សាខន ដែលត្រូវបានផ្សឹកដោយបង្ខំ ហើយចាប់បញ្ជូនទៅវៀតណាមពេលថ្មីៗនេះព្រោះពួកគេព្រួយបារម្ភយ៉ាងខ្លាំងពីស្ថានភាពអតីតព្រះសង្ឃ ជាចៅអធិការវត្តខ្មែរអង្គនេះថាមិនដឹងជាស្លាប់ឬរស់ឬក៏ទទួលរងនូវការធ្វើទារុណកម្មយ៉ាងណានោះ។

លិខិតបានបន្តដោយស្នើសុំអគ្គរដ្ឋទូតវៀតណាមង្វៀនចៀនថាំងមេត្តាផ្តល់លទ្ធភាពឱ្យលោកនិងសហការីបានទៅជួបលោកទឹម សាខន និងឃើញស្ថានភាពជាក់ស្តែងដោយផ្ទាល់ដើម្បីឱ្យដឹងថាតើការពិតយ៉ាងណាខ្លះជាការជួយកុំអោយមានការរំដើបរំជួលពី

សំណាក់ពលរដ្ឋខ្មែរជាច្រើនលាន នាក់ពាក់ព័ន្ធលើករណីនេះ និង ស្ថានភាពសិទ្ធិមនុស្សទូទៅដែល កំពុងរងការចោទប្រកាន់ចំពោះ អាជ្ញាធរវៀតណាមពីការរំលោភ បំពានលើជនជាតិដើម ពិសេស ចំពោះបងប្អូនខ្មែរកម្ពុជាក្រោម នោះ។

ពេលជំណាលគ្នានេះដែរ សេចក្តីថ្លែងការណ៍របស់សហគមន៍ខ្មែរកម្ពុជាក្រោមដែលចុះហត្ថលេខាដោយនាយកប្រតិបត្តិលោកថាច់សេដ្ឋាបានសរសេរថា សហគមន៍ខ្មែរកម្ពុជាក្រោម មានសេចក្តីសោកស្តាយជាខ្លាំងចំពោះប្រសាសន៍របស់លោកង្វៀន ចៀនថាំង ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា ដែលបានប្រាប់បណ្តាញសារពត៌មាននៅក្នុងសន្និសីទកាសែតកាលពីថ្ងៃទី២៤ ខែសីហា ២០០៧នេះ ដោយលោកសេដ្ឋាបញ្ជាក់ថានេះជាសកម្មភាពនយោបាយការទូតថ្មីមួយទៀតរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងការបំភ្លៃការពិតដើម្បីបំភាន់សាធារណមតិជាតិនិងអន្តរជាតិ អំពីការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសវៀតណាម ពិសេស ចំពោះប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម។ លោកសេដ្ឋាបានបញ្ជាក់ទៀតថា ប្រសាសន៍របស់លោកង្វៀនចៀនថាំងពុំបានឆ្លុះបញ្ចាំងការពិតដែលកំពុងកើតមានចំពោះប្រជារាស្ត្រខ្មែរកម្ពុជាក្រោមនិងពុំហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដែលបានធ្វើមកលើប្រជារាស្ត្រនិងព្រះសង្ឃខ្មែរកម្ពុជាក្រោមឡើយ។

សហគមន៍ខ្មែរកម្ពុជាក្រោម បានធ្វើការកត់សម្គាល់ប្រសាសន៍របស់លោកទូតយួនហើយបញ្ជាក់ជូនសាធារណមតិជាតិនិងអន្តរជាតិអំពីស្ថានភាពពិតដែលកំពុងកើតមានចំពោះប្រជារាស្ត្រនិងព្រះសង្ឃខ្មែរកម្ពុជាក្រោមដូចខាងក្រោមៈ

១-ឯកឧត្តមឯកអគ្គរដ្ឋទូតបានថ្លែងបញ្ជាក់ថា ព្រះតេជគុណទឹម សាខនកំពុងជាប់ឃុំនៅប្រទេសវៀតណាមក្រោមបទចោទប្រកាន់ថា "បានធ្វើឱ្យបែកបាក់ផ្ទៃកសាសនារវាងប្រទេសទាំងពីរ (កម្ពុជា-វៀតណាម)" ។ ការថ្លែងនេះផ្ទុយទាំងស្រុងនឹងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាលវៀតណាមកាលពីថ្ងៃទី២ ខែសីហា ឆ្នាំ ២០០៧ ដែលបានចោទប្រកាន់ព្រះតេជគុណទឹម សាខនថា "បានឆ្លងដែលចូលប្រទេសវៀតណាម ដោយខុសច្បាប់និងធ្វើសកម្មភាពបំបែកបំបាក់មិត្តភាពសាមគ្គីភាពកម្ពុជា-វៀតណាម" ។ ទោះបីការថ្លែងមានការខុសគ្នាយ៉ាងណាក៏ដោយ ក៏ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ព្រះតេជគុណទឹម សាខនបានប្រព្រឹត្តបទល្មើសណាមួយក្នុងទឹកដីវៀតណាមឬនៅពីក្រោយខ្នងសកម្មភាពណាមួយ នោះក៏គ្មានដែរ ។ការបំបែកបំបាក់ឬការកាត់ផ្តាច់ទំនាក់ទំនងព្រះពុទ្ធសាសនាខ្មែររវាងកម្ពុជា និង កម្ពុជាក្រោមមិនមែនព្រះតេជគុណទឹម សាខនទេ តែគឺអាជ្ញាធរអាណានិគមវៀតណាមបច្ចុប្បន្ននេះតែម្តង ជាក់ស្តែងដូចវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរងនៅខេត្តឃ្លាំង ត្រូវអាជ្ញាធរអាណានិគមវៀតណាមបិទទ្វាររហូតដល់សព្វថ្ងៃជាដើម។

ព្រះតេជគុណទឹម សាខនត្រូវបានចាប់ផ្សឹកដោយអំណាចសម្តេចសង្ឃនាយកនៃប្រទេសកម្ពុជា ដោយបានចោទប្រកាន់ពីបទធ្វើសកម្មភាពបំបែកបំបាក់សាមគ្គីភាពកម្ពុជា-វៀតណាម. ហេតុដូចម្តេចបានជាត្រូវជាប់ឃុំឃាំងនិងកាត់ទោសនៅប្រទេសវៀតណាម? តើសកម្មភាពរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបែបនេះ ចង់បង្ហាញអំពីឥទ្ធិពលអំណាចអាណានិគមរបស់ខ្លួននៅលើទឹកដីកម្ពុជាដូចក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ឬយ៉ាងណា?

២-លោកអគ្គរដ្ឋទូតវៀតណាមបានថ្លែងថារដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបានគោរពសិទ្ធិសេរីភាពជំនឿសាសនារបស់ជនជាតិដើមទាំង៥៤យ៉ាងត្រឹមត្រូវរួមទាំងខ្មែរផង ។ នេះមិនមែនជាការពិតទេ។ប្រជារាស្ត្រនិងព្រះសង្ឃខ្មែរកម្ពុជាក្រោមកំពុងទទួលរងនូវការរំលោភយ៉ាងធ្ងន់ធ្ងរពីសំណាក់អាជ្ញាធរ

អាណានិគមវៀតណាម ដោយអាជ្ញាធរអាណានិគមវៀតណាមបានកែប្រែទំនៀមទំលាប់ព្រះពុទ្ធសាសនា ចាប់បង្ខំព្រះសង្ឃឱ្យធ្វើពលកម្មដូចគ្រហស្ថមានជីកប្រឡាយ ធ្វើស្រែចំការ ចិញ្ចឹមសត្វពាហនៈ, រាល់កម្មវិធីបុណ្យទានតាមបែបសាសនា ត្រូវបានកំណត់, គ្រប់វត្តអារាមត្រូវបង់វិភាគទានជូនរដ្ឋជាដើម ។ថ្មីៗនេះ អាជ្ញាធរអាណានិគមវៀតណាមបានចាប់ព្រះសង្ឃខ្មែរកម្ពុជាក្រោមផ្សឹកចំនួន១៦អង្គហើយ៥អង្គត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី២ទៅ៤ឆ្នាំ, សាលារៀនពុទ្ធសាសនាខ្មែរត្រូវបង្ខំឱ្យរៀនទ្រឹស្តីហូ ជីមិញជាចំបង និងមានការហាមឃាត់ការទាក់ទងរវាងព្រះសង្ឃពីវត្តមួយទៅវត្តមួយ, ការរស់នៅរបស់ព្រះសង្ឃនិងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមស្ថិតនៅក្នុងការភ័យខ្លាចជានិច្ច ។

៣-លោកអគ្គរដ្ឋទូតវៀតណាមបានទទួលស្គាល់ថា ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមពិតជាមានបញ្ហានិងមានការលំបាកច្រើន, តែបច្ចុប្បន្នមានការរីកចំរើនដោយសារអត្រានៃភាពក្រីក្របានថយចុះ ។ បើនិយាយអំពីភាពក្រីក្ររបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម មានតែនៅក្នុងរបបកុម្មុយនីស្តវៀតណាមពីឆ្នាំ១៩៧៥មកដល់បច្ចុប្បន្នតែប៉ុណ្ណោះ ដែលបានធ្វើឱ្យប្រជារាស្ត្រខ្មែរជួបប្រទះភាពក្រីក្រជាងគេបំផុត ។ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជាង៩៥% ជាកសិករដែលមានដីធ្លីសំបូរដោយដីជាតិសំរាប់ធ្វើកសិកម្មតាំងពីបុរាណរៀងរហូតមក ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ អាជ្ញាធរអាណានិគមវៀតណាមបានរឹបអូសយកដីស្រែចំការរបស់ប្រជារាស្ត្រខ្មែរទាំងស្រុង រួចហើយទើបបែងចែកក្នុងគ្រួសារនីមួយៗតែបន្តិចបន្តួច ។ បច្ចុប្បន្ន ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបានធ្លាក់ខ្លួនក្រនិងក្លាយជាទាសករនៅលើទឹកដីកំណើតរបស់ខ្លួនយ៉ាងខ្លោចផ្សាបំផុត, គ្រួសារខ្មែរនីមួយៗបានបង្ខំចិត្តទៅស៊ីឈ្នួលជនជាតិវៀតណាមតាមខេត្តនានាស្ទើរស្ទាត់ស្រុក ។តើត្រង់ណាដែលថាប្រជារាស្ត្រខ្មែរកម្ពុជាក្រោមរីកចំរើនល្អប្រសើរ?

ចំពោះបំណងល្អរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដែលថានឹងរៀបចំឱ្យមានដំណើរទស្សនកិច្ចរបស់អ្នកកាសែតទៅកាន់តំបន់ប្រជារាស្ត្រខ្មែររស់នៅដើម្បីបានឃើញទិដ្ឋភាពជាក់ស្តែងនោះ, សហគមន៍ខ្មែរកម្ពុជាក្រោមយល់ឃើញថា រដ្ឋាភិបាលវៀតណាមគួរតែបើកទូលាយឱ្យក្រុមសិទ្ធិមនុស្សជាតិ-អន្តរជាតិនិងបណ្តាញសារពត៌មានសេរីចុះទៅដល់កន្លែងប្រជារាស្ត្រខ្មែររស់នៅផ្ទាល់ដោយសេរី ដោយពុំមានការរៀបចំពីរដ្ឋាភិបាលកុម្មុយនីស្តវៀតណាម ទើបជាការល្អពីព្រោះការរៀបចំដើម្បីបំភាន់សាធារណមតិជាតិ អន្តរជាតិ គ្មាននរណាពូកែជាងពួកកុម្មុយនីស្តទេ ដូចជាពួកកុម្មុយនីស្តកម្ពុជានិងកុម្មុយនីស្តវៀតណាមជាដើម ។

សូមបញ្ជាក់ថា យួនកំពុងបន្តតំកើងកម្ពុជាក្នុងភាពជាប្រទេសជិតខាងមានប្រពៃណីជាមិត្តភាពនិងសហប្រតិបត្តិការល្អជាមួយយួននៅពេលនេះ ដោយកម្ពុជាបានបង្ហាញភាពស្មោះត្រង់ជួយចាប់ព្រះតេជគុណទីម សាខនឱ្យយួនដាក់គុក ។

លោកខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជានិងជារដ្ឋមន្ត្រីក្រសួងពត៌មានបានថ្លែងអំពីសារៈសំខាន់នៃថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥គឺថ្ងៃដែលប្រទេសយួនប្រកាសឯករាជ្យរបស់ខ្លួននោះ ដោយលោកបានសម្តែងថ្លែងអំណរគុណចំពោះវៀតណាមដែលបានជួយកម្ពុជាលើគ្រប់វិស័យ ដោយរួមទាំងវិស័យផ្សព្វផ្សាយពត៌មានផងដែរ ។ លោករដ្ឋមន្ត្រីពត៌មានខ្មែរបានថ្លែងថា បណ្តាញផ្សព្វផ្សាយនៃប្រទេសទាំងពីរបានធ្វើការងាររីកចំរើនគួរអោយកត់សម្គាល់ហើយថាភាគីទាំងពីរគួរតែលើកតំកើងផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកថែមទៀតដើម្បីលើកតំកើងការយល់ដឹងរវាងអ្នកកាសែតរបស់ប្រទេសទាំងពីរ, នេះតាមប្រភពពីភ្នាក់ងារពត៌មានវៀតណាមចេញផ្សាយថ្ងៃទី ២៧ សីហា ២០០៧នេះ ៕